# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌
លេខ ២៣៨ ស្ជួន រប.៩៣

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

**លោកប្រធានតុលាការគ្រប់ ខេត្ត ក្រុង**

**រដ្ឋអាជ្ញាអមតុលាការ ខេត្ត ក្រុង**

**កម្មវត្ថុ:** អំពីឯករាជ្យភាពនៃចៅក្រម

**យោង:** បទបញ្ញាត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាអន្តរកាល ដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័តកាលពីថ្ងៃទី១០-០៩-០២ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងដូចបានជម្រាបជូនខាងលើ ខ្ញុំសូមជម្រាបអស់លោកជាចៅក្រម និងរដ្ឋអាជ្ញា នៅតុលាការខេត្ត ក្រុងទូទាំងប្រទេសជ្រាបថា ដើម្បីរក្សាភាពឯករាជ្យនៃចៅក្រមនោះ យើងជាចៅក្រមក្តី រដ្ឋអាជ្ញាអមតុលាការក្តី មិនត្រូវចូលរួមក្នុងកិច្ចការទាំងឡាយដែលទាក់ទងដល់ការបោះឆ្នោតដែលធ្វើឡើងដោយគណបក្សនានាពេលបច្ចុប្បន្ននេះឡើយ ប៉ុន្តែបើមានជនណាមួយស្នើឲ្យបំភ្លឺបញ្ហាច្បាប់ដែលទាក់ទងដល់កិច្ចការបោះឆ្នោតនោះ ចៅក្រមក្តី រដ្ឋអាជ្ញាក្តី អាចជួយបំភ្លឺបាន ។

យើងសង្ឃឹមជឿជាក់ថា អស់លោកពិតជាយកចិត្តទុកដាក់គោរពតាមច្បាប់ដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័តរួចមកហើយនោះជាពុំខាន ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៣

**ហត្ថលេខា និងត្រា**

**អ៊ុក ប៊ុនឈឿន**

<u>ចម្លងជូន</u>

-ខុទ្ទកាល័យគណៈកម្មាធិការកណ្តាល
-គណៈកម្មាធិការបក្សខេត្ត ក្រុង
-តុលាការកំពូល
-មហាអយ្យការអមតុលាការកំពូល
-ដើម្បីជ្រាបជាព័ត៌មាន